ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# លទ្ធផលបឋមនៃ
# អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥



វិទ្យាស្ថានជាតិស្ថិតិ

ក្រសួងផែនការ

# មាតិកា


**តារាង និងរូបភាព**..........២
**អក្សរកាត់**..........៣
**បុព្វកថា**..........៤
**អារម្ភកថា**..........៦
**ផែនទីព្រះរាជាណាចក្រកម្ពុជា**..........៨
**ជំពូក ១**..........**៩**
សេចក្តីផ្តើម..........**៩**
**ជំពូក ២**..........**១៨**
វិធីសាស្ត្រអង្កេត..........១៨
**ជំពូក ៣**..........**២៧**
ចរិតលក្ខណៈប្រជាសាស្ត្រ..........២៧
**ជំពូក ៤**..........**៣១**
ប្រជាជនក្នុងអាយុធ្វើការ..........៣១
**ជំពូក ៥**..........**៣៧**
ភាពមានការងារធ្វើការ..........៣៧
**ឧបសម្ព័ន្ធ**..........**៤៤**
**កម្រងសំណួរគ្រួសារ ២០២៥**..........**៤៤**

# តារាង និង រូបភាព


**ជំពូកទី ២**.................................................................................................................១៨
តារាង ២.១ ភូមិ និងគ្រួសារសំណាកគំរូសម្រាប់អង្កេតកម្លាំងពលកម្ម កម្ពុជា ឆ្នាំ២០២៥.........២១
តារាង ២.២ ការបែងចែកសំណាកគំរូតាមតំបន់ទីប្រជុំជន និងជនបទ ក្នុងរាជធានីខេត្តសម្រាប់ ២១
**ជំពូកទី ៣**..................................................................................................................**២១**
តារាង ៣.១. សូចនាករទីផ្សារការងារសំខាន់ៗ...........................................................................២៧
រូបភាព ៣.១ ៖ ពីរ៉ាមីតប្រជាជនតាមភេទ និងក្រុមអាយុ ឆ្នាំ២០២៥ .........................................២៨
តារាង ៣.២. ភាគរយប្រជាជន តាម ភេទ ក្រុមអាយុ និងតំបន់ភូមិសាស្ត្រ .............................២៨
តារាង ៣.៣ ទំហំគ្រួសារ តាម តំបន់ និងភេទ ឆ្នាំ២០២៥.................................................................២៩
រូបភាព ៣.២ ៖ ភាគរយមេគ្រួសារតាមភេទ និងតំបន់ ឆ្នាំ២០២៥.......................................... ៣០
តារាង ៣.៤ ៖ សមាមាត្រអ្នកនៅក្នុងបន្ទុកតាមតំបន់ ឆ្នាំ២០២៥ ......................................... ៣១
**ជំពូកទី ៤** ................................................................................................................... ៣១
ប្រជាជនក្នុងអាយុធ្វើការ...................................................................................................... ៣១
តារាង ៤.១៖ ការបែងចែកប្រជាជនក្នុងអាយុធ្វើការ តាមក្រុមអាយុ ភេទ និងតំបន់ ឆ្នាំ ២០២៥ .... ៣១
រូបភាព ៤.១៖ ការបែងចែកប្រជាជនក្នុងអាយុធ្វើការ តាមក្រុមអាយុ និងភេទ ឆ្នាំ ២០២៥ ...... ៣២
តារាង ៤.២៖ អត្រាចូលរួមក្នុងកម្លាំងពលកម្ម តាមក្រុមអាយុ ភេទ និងតំបន់ ឆ្នាំ ២០២៥ ....... ៣៣
រូបភាព ៤.២៖ អត្រាចូលរួមក្នុងកម្លាំងពលកម្ម តាមក្រុមអាយុ និងភេទ ឆ្នាំ ២០២៥............... ៣៤
តារាង ៤.៣៖ ប្រជាជនដែលមានសកម្មភាពសេដ្ឋកិច្ច តាមក្រុមអាយុ ឆ្នាំ ២០២៥................ ៣៦
តារាង ៤.៤ ៖ ប្រជាជនដែលមានសកម្មភាពសេដ្ឋកិច្ច តាមភេទ ឆ្នាំ ២០២៥....................... ៣៦
**ជំពូកទី ៥** ................................................................................................................. ៣៧
តារាង ៥.១៖ការបែងចែកភាគរយប្រជាជនមានការងារធ្វើ តាមក្រុមអាយុ តំបន់និងភេទឆ្នាំ ២០២៥........................................................................................................................ ៣៨
តារាង ៥.២៖ការបែងចែកប្រជាជនមានការងារធ្វើ តាមវិស័យឧស្សាហកម្មនិងភេទ ឆ្នាំ ២០២៥.... ៣៩
តារាង ៥.៣៖ ការបែងចែកប្រជាជនមានការងារធ្វើ តាមប្រភេទមុខរបរ និងភេទ ឆ្នាំ ២០២៥ ...៤០
តារាង ៥.៤ ស្ថានភាពប្រជាជនដែលមានការងារធ្វើឆ្នាំ ២០២៥ ..............................................៤១
តារាង ៥.៥៖ ចំនួនកម្លាំងពលកម្ម អ្នកមានការងារធ្វើ និងអ្នកគ្មានការងារធ្វើ តាមកម្រិតអប់រំ ឆ្នាំ ២០២៥.........................................................................................................................៤២
រូបភាព ៥.១៖ អត្រាអត់ការងារធ្វើរបស់យុវជន តាមភេទ (១៥-២៤ ឆ្នាំ) និង កម្រិតអប់រំ ឆ្នាំ ២០២៥........................................................................................................................ ៤៣
**ឧបសម្ព័ន្ធ** ..................................................................................................................**៤៤**
**កម្រងសំណួរគ្រួសារ ២០២៥**..............................................................................................**៤៤**

# អក្សរកាត់

| | |
|---|---|
| CAPI | ការសម្ភាសផ្ទាល់ដោយប្រើកុំព្យូទ័រជាជំនួយ |
| CLFS | ការអង្កេតកម្លាំងពលកម្មកម្ពុជា |
| GPC | ជំរឿនប្រជាជនទូទៅកម្ពុជា |
| ILO | អង្គការអន្តរជាតិខាងការងារ |
| KIR | របាយការណ៍សូចនាករសំខាន់ៗ |
| LFPR | អត្រាចូលរួមក្នុងកម្លាំងពលកម្ម |
| MLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ |
| NEET | មិនមានការងារ មិនបានសិក្សា និងមិនបានបណ្តុះបណ្តាល |
| NGO | អង្គការមិនមែនរដ្ឋាភិបាល |
| NIS | វិទ្យាស្ថានជាតិស្ថិតិ |
| PSU | ឯកតាគំរូដំបូង |
| RCI | សូចនាករចំណាយក្នុងការជ្រើសរើសបុគ្គលិក |
| RGC | រាជរដ្ឋាភិបាលកម្ពុជា |
| SD | គម្លាតស្តង់ដារ |
| SDG | គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព |
| SDM | វិធីសាស្ត្រថ្ងៃតាមស្តង់ដារ |
| SNA | ប្រព័ន្ធគណនេយ្យជាតិ |
| UNDP | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ |
| WB | ធនាគារពិភពលោក |

# បុព្វកថា

របាយការណ៍លទ្ធផលបឋមនៃ **អង្កេតកម្លាំងពលកម្មកម្ពុជាឆ្នាំ២០២៥** បានផ្តល់ទិន្នន័យស្ថិតិសំខាន់ៗ រួមមាន៖ កម្លាំងពលកម្ម ទីផ្សារពលកម្ម អ្នកធ្វើការតាមវិស័យ អត្រាចូលរួមក្នុងកម្លាំងពលកម្ម អត្រាអត់ការងារធ្វើ ស្ថានភាពការងារ ចំនួនម៉ោងធ្វើការ លក្ខណៈសង្គមសេដ្ឋកិច្ច និងសូចនាករផ្សេងៗទៀត។ របាយការណ៍លទ្ធផលបឋមនេះ ត្រូវបានដឹកនាំអនុវត្តប្រមូលទិន្នន័យចាប់ពីថ្ងៃទី២៥ ខែតុលា ជាលើថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៥ ដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ គ្របដណ្តប់ទូទាំងព្រះរាជាណាចក្រកម្ពុជា។

អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ ត្រូវបានប្រមូលទិន្នន័យនៅក្នុងបរិបទដែលប្រទេសកម្ពុជាបាននិងកំពុងជួបប្រទះបញ្ហាជម្លោះព្រំដែន កម្ពុជា-ថៃ ដែលបានកើតឡើងក្នុងឆ្នាំ២០២៥ ហើយជម្លោះព្រំដែននេះ បានជះឥទ្ធិពលទៅលើលំហូរចំណាកស្រុក នៃពលករខ្មែរដែលបានវិលត្រឡប់ពីប្រទេសថៃមកកាន់ប្រទេសកម្ពុជាវិញ។ ភាពតានតឹងនេះ បានបង្កផលប៉ះពាល់ដោយផ្ទាល់ដល់ជីវភាពរស់នៅរបស់កម្មករចំណាកស្រុក និងក្រុមគ្រួសាររបស់ពួកគេ ទាំងក្នុងអំឡុងពេល និងក្រោយពេលនៃជម្លោះព្រំដែននេះ។

របាយការណ៍អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ មានគោលបំណងផ្តល់ទិន្នន័យស្ថិតិ និងសូចនាករគន្លឹះសម្រាប់គាំទ្រដល់ការធ្វើសេចក្តីសម្រេចចិត្តដោយផ្អែកលើភស្តុតាង ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តផែនការយុទ្ធសាស្ត្រ និងគោលនយោបាយជាតិសំខាន់ៗ រួមមាន៖ យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា, ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ, គោលដៅអភិវឌ្ឍប្រកបដោយចីរភាព ឆ្នាំ២០១៦-២០៣០, គោលនយោបាយជាតិស្តីពីមុខរបរនិងការងារ និងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម។ លើសពីនេះ ទិន្នន័យទាំងនេះ ក៏ជាប្រភពព័ត៌មានដ៏សំខាន់សម្រាប់អ្នករៀបចំ គោលនយោបាយ ក្រុមអ្នកស្រាវជ្រាវ ដៃគូអភិវឌ្ឍន៍ និងសាធារណជន ក្នុងការយល់អំពីកម្លាំងពលកម្ម ស្ថានភាពការងារ អត្រាគ្មានការងារធ្វើ ម៉ោងធ្វើការ និងលក្ខណៈសង្គម-សេដ្ឋកិច្ចផ្សេងៗទៀតរបស់ប្រជាជនកម្ពុជា។ លទ្ធផលនៃការអង្កេតនេះ នឹងដើរតួនាទីយ៉ាងសំខាន់ក្នុងការវិភាគស្ថានភាពទីផ្សារការងារ សូចនាករការងារសមរម្យ និងការជំរុញកំណើនសេដ្ឋកិច្ច ផងដែរ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតជូនចំពោះ ប្រមុខរាជរដ្ឋាភិបាលកម្ពុជា និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានផ្តល់ការគាំទ្រផ្នែកហិរញ្ញវត្ថុសម្រាប់ការអនុវត្តការងារអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥។ ខ្ញុំក៏សូមថ្លែងអំណរគុណដល់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អង្គការអន្តរជាតិខាងការងារ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ និងធនាគារពិភពលោក សម្រាប់ការគាំទ្រផ្នែកបច្ចេកទេស

និងការចូលរួមយ៉ាងសកម្មក្នុងដំណើរការអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ នេះ។ ជាពិសេស លទ្ធផលគួរជាទីមោទនៈនេះ សម្រេចទៅបានដោយមានការចូលរួមខិតខំប្រឹងប្រែងបំពេញភារកិច្ចប្រកបដោយ ស្មារតីយកចិត្តទុកដាក់ខ្ពស់របស់ក្រុមប្រឹក្សាភិបាលនៃវិទ្យាស្ថានជាតិស្ថិតិ ថ្នាក់ដឹកនាំនៃវិទ្យាស្ថានជាតិស្ថិតិ គណៈកម្មការបច្ចេកទេសអន្តរក្រសួង ក្រុមការងារបច្ចេកទេស មន្ត្រីអង្កេតទាំងអស់ អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ព្រមទាំងការចូលរួមយ៉ាងសកម្មរបស់ប្រជាពលរដ្ឋក្នុងការផ្តល់បទសម្ភាសន៍ ដែលធ្វើឱ្យការងារអង្កេតនេះឈានសម្រេចបាន ជោគជ័យ។

**រដ្ឋមន្ត្រីក្រសួងផែនការ**

**ប៊ិន ត្រឈៃ**

# អារម្ភកថា

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ សូមបង្ហាញនូវរបាយការណ៍លទ្ធផលបឋមនៃការវិភាគទិន្នន័យអង្កេតកម្លាំងពលកម្មកម្ពុជាឆ្នាំ២០២៥ ដែលបានពីការប្រមូលទិន្នន័យចាប់ពីថ្ងៃទី២៥ ខែតុលា ដល់ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៥ គ្របដណ្តប់ទូទាំងទឹកដីនៃព្រះរាជាណាចក្រកម្ពុជា មានសំណាកគំរូប្រមាណ ៩.៩១២ គ្រួសារ ដោយមានរបាយស្ថិតនៅទូទាំង ២៥រាជធានី ខេត្តទូទាំងប្រទេសកម្ពុជា។ អង្កេតកម្លាំងពលកម្មកម្ពុជាគឺជាសកម្មភាពស្ថិតិជាតិដ៏សំខាន់មួយ ក្នុងចំណោមសកម្មភាពស្ថិតិផ្លូវការជាច្រើនដែលបានធ្វើឡើងដោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ។ អង្កេតកម្លាំងពលកម្មកម្ពុជាឆ្នាំ២០២៥ គឺជាអង្កេតលើកទី៥ បន្ទាប់ពីបានអនុវត្តនៅក្នុងឆ្នាំ២០០០ ២០០១ ២០១២ និង២០១៩ ដែលបានសហប្រតិបត្តិការបច្ចេកទេសជាមួយភាគីពាក់ព័ន្ធសំខាន់ៗមួយចំនួនដូចជា ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អង្គការអន្តរជាតិខាងការងារ អង្គការកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ និងធនាគារពិភពលោក។

លទ្ធផលបឋមនៃការអង្កេតនេះ បានផ្តល់នូវព័ត៌មានសំខាន់ស្តីពីស្ថានភាព និងលក្ខណៈនៃកម្លាំងពលកម្មនៅកម្ពុជា ដោយផ្តោតលើសូចនាករសំខាន់ៗនៃទីផ្សារការងារ រួមមាន ភាពមានការងារធ្វើ និងគ្មានការងារធ្វើ អត្រាការចូលរួមក្នុងកម្លាំងពលកម្ម លក្ខខណ្ឌការងារ ព្រមទាំងសូចនាករពាក់ព័ន្ធផ្សេងៗទៀត។ របាយការណ៍លទ្ធផលបឋមនេះ បានបង្ហាញនូវការវិភាគទិន្នន័យសំខាន់ៗក្នុងទម្រង់សង្ខេប ដើម្បីផ្តល់ព័ត៌មានឱ្យបានទាន់ពេលវេលាអំពីស្ថានភាពទីផ្សារការងារបច្ចុប្បន្ន ជូនដល់ស្ថាប័នរាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ អ្នកស្រាវជ្រាវ និងអ្នកប្រើប្រាស់ទិន្នន័យស្ថិតិផ្លូវការ។ ជាមួយគ្នានេះ លទ្ធផលទាំងនេះក៏ផ្តល់នូវទិដ្ឋភាពទូទៅអំពីទំហំ និងចរិតលក្ខណៈនៃកម្លាំងពលកម្ម ព្រមទាំងជាភស្តុតាងមូលដ្ឋានដ៏សំខាន់សម្រាប់ការរៀបចំគោលនយោបាយ ការរៀបចំផែនការសេដ្ឋកិច្ច-សង្គម និងការតាមដានការវិវត្តនៃទីផ្សារការងារ។

អង្កេតកម្លាំងពលកម្មកម្ពុជាឆ្នាំ២០២៥ ត្រូវបានអនុវត្តឡើង ដើម្បីប្រមូលព័ត៌មានសំខាន់ៗពាក់ព័ន្ធនឹងលក្ខណៈប្រជាសាស្ត្រ សកម្មភាពសេដ្ឋកិច្ច មុខរបរ វិស័យសេដ្ឋកិច្ច ម៉ោងធ្វើការ និងស្ថានភាពការងាររបស់បុគ្គល។ ទិន្នន័យដែលប្រមូលបានទាំងនេះ មានសារៈសំខាន់ក្នុងការផ្តល់ការយល់ដឹងអំពីស្ថានភាពការវិវត្ត និងបម្រែបម្រួលនៃទីផ្សារការងារនៅកម្ពុជា។

នៅក្នុងដំណើរការអនុវត្តអង្កេតនេះ ការប្រមូលទិន្នន័យត្រូវបានធ្វើទំនើបកម្មតាមរយៈការផ្លាស់ប្តូរពីវិធីសាស្ត្រប្រពៃណីប្រើប្រាស់ក្រដាស (PAPI) ទៅជាវិធីសាស្ត្រប្រើប្រាស់បច្ចេកវិទ្យាទំនើបតាមរយៈថាប្លេតសម្រាប់ការប្រមូល ការបញ្ជូន និងការគ្រប់គ្រងទិន្នន័យប្រកបដោយប្រសិទ្ធភាព និងភាពទាន់ពេលវេលា។ ព័ត៌មានដែលទទួលបានពីអង្កេតកម្លាំងពលកម្មនេះ មានគោលបំណងគាំទ្រដល់ការរៀបចំ គោលនយោបាយសំដៅលើការលើកកម្ពស់ឱកាសការងារ និងការកែលម្អលក្ខខណ្ឌការងារនៅកម្ពុជា។ ជាមួយគ្នានេះ ស្ថិតិកម្លាំងពលកម្មក៏មានតួនាទីសំខាន់ក្នុងការរៀបចំផែនការអភិវឌ្ឍជាតិ ការតាមដានត្រួតពិនិត្យ និងវាយតម្លៃលើវឌ្ឍនភាពនៃយុទ្ធសាស្ត្រអភិវឌ្ឍជាតិ ព្រមទាំងការអនុវត្តគោលនយោបាយទីផ្សារការងារផងដែរ។

ជាទីបញ្ចប់ ខ្ញុំសូមថ្លែងអំណរគុណចំពោះរាជរដ្ឋាភិបាលកម្ពុជា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលបានគាំទ្រផ្នែកហិរញ្ញវត្ថុ និងសូមថ្លែងអំណរគុណោះជាពិសេសជូនចំពោះ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងផែនការ ឯកឧត្តមប្រធាន សមាជិក សមាជិកានៃក្រុមប្រឹក្សាភិបាលស្ថិតិនៃវិទ្យាស្ថានជាតិស្ថិតិ ដែលបានខិតខំប្រឹងប្រែងក្នុងការដឹកនាំតម្រង់ទិស និងផ្តល់អនុសាសន៍ដ៏ខ្ពង់ខ្ពស់សម្រាប់ដំណើរការ និងការប្រព្រឹត្តទៅនៃអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥។ ខ្ញុំក៏សូមអរគុណចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី ថ្នាក់ដឹកនាំវិទ្យាស្ថានជាតិស្ថិតិ តំណាងក្រសួង ស្ថាប័ន ក្រុមការងារបច្ចេកទេសអង្កេតកម្លាំងពលកម្ម ក្រុមការងារស្នូលនៃវិទ្យាស្ថានជាតិស្ថិតិ ក្រុមអ្នកជំនាញការនៃអង្គការអន្តរជាតិខាងការងារ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ និងធនាគារពិភពលោក មន្ត្រីក្រុមការងារបច្ចេកទេស ដែលបានសហការគាំទ្របច្ចេកទេសនៅក្នុងការពង្រឹងគុណភាពទិន្នន័យអង្កេតនេះឱ្យទទួលបានជោគជ័យ និងក៏សូមអរគុណចំពោះមន្ត្រីអង្កេតទាំងអស់ ព្រមទាំងប្រជាជនដែលបានចូលរួមសម្ភាសន៍ផ្តល់ចម្លើយសម្រាប់អនុវត្តអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ ឱ្យទទួលបានទិន្នន័យប្រកបដោយគុណភាព និងប្រសិទ្ធភាព៕

**នាយកវិទ្យាស្ថានជាតិស្ថិតិ**

**ណោ វ៉ាន់ឌី**

វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ
រាជធានីភ្នំពេញ
ខែឧសភា ឆ្នាំ២០២៦

# ផែនទីព្រះរាជាណាចក្រកម្ពុជា



# ជំពូក ១

## សេចក្តីផ្តើម

អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ គឺជាការអនុវត្តលើកទី៥ បន្ទាប់ពីការអង្កេតនៅឆ្នាំ ២000 ២00១ ២០១២ និង ២០១៩។ វិទ្យាស្ថានជាតិស្ថិតិ (វ.ជ.ស.) បានសហការជាមួយ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ អង្គការអន្តរជាតិខាងការងារ អង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ និងធនាគារពិភពលោក ក្នុងការអនុវត្តការអង្កេតនេះ។ ការប្រមូលទិន្នន័យនៅមូលដ្ឋានបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី ២៥ ខែតុលា ដល់ថ្ងៃទី ១៩ ខែវិច្ឆិកា ឆ្នាំ ២០២៥។ ការគាំទ្រផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេសសម្រាប់ការអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ ត្រូវបានផ្តល់ដោយ រាជរដ្ឋាភិបាលកម្ពុជា អង្គការអន្តរជាតិខាងការងារ អង្គការសហប្រជាជាតិដើម្បីការអភិវឌ្ឍ និងធនាគាពិភពលោក។

អង្គការអន្តរជាតិខាងការងារ បានផ្តល់ជំនួយបច្ចេកទេសសម្រាប់ការអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ ២០២៥ ហើយបានគាំទ្រក្នុងការប្រមូលទិន្នន័យដើម្បីត្រួតពិនិត្យ និងវាយតម្លៃ ចំនួនប្រជាជន ភាពមានការងារធ្វើ ភាពគ្មានការងារធ្វើ និងការងារសមរម្យ។

អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ គឺជាអង្កេតគ្រួសារ ដែលត្រូវបានអនុវត្តន៍ដំណើរវិទ្យាស្ថានជាតិស្ថិតិ ក្រសួងផែនការ និងមានការគាំទ្របច្ចុកទេសពីអង្គការអន្តរជាតិខាងការងារ អង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ និងធនាគារពិភពលោក ។ នេះជាអង្កេតទូទាំងប្រទេសលើកទីប្រាំ ដែលកម្ពុជាបានប្រមូលទិន្នន័យអំពីការងារ និងភាពមានការងារធ្វើ តាមរយៈអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥។ អង្កេតកម្លាំងពលកម្មកម្ពុជាដែលបានដំណើរការកន្លងមក ក៏បានសហការជាមួយដៃគូអភិវឌ្ឍន៍មួយចំនួនផងដែរ។

របាយការណ៍សូចនាករសំខាន់ៗនេះផ្តល់នូវទិដ្ឋភាពទូទៅដំបូងនៃការរកឃើញដែលបានជ្រើសរើសពីអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ ។ ការវិភាគដ៏ទូលំទូលាយនៃទិន្នន័យនឹងត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ចុងក្រោយ ដែលគ្រោងនឹងចេញផ្សាយនៅក្នុងខែមិថុនា ឆ្នាំ២០២៦។

### ១.១ សាវតារ

អាទិភាពគោលនយោបាយ និងគោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា រួមមាន ការពង្រីកទីផ្សារការងារ ការទទួលបានប្រាក់ចំណូលខ្ពស់ លក្ខខណ្ឌការងារល្អ និងការយកចិត្តទុកដាក់កាន់តែខ្លាំងលើសុខុមាលភាពរបស់កម្មករ និងនិយោជិត ទាំងក្នុងប្រព័ន្ធ និងក្រៅប្រព័ន្ធសេដ្ឋកិច្ច។ ទិន្នន័យ និងលទ្ធផលដែលទទួលបានពីការអង្កេតនេះ នឹងបម្រើដល់ការតាមដានវឌ្ឍនភាព ក្នុងការសម្រេចឱ្យបាននូវអាទិភាព និងគោលដៅយុទ្ធសាស្ត្រទាំងនេះ។

ការអង្កេតនេះត្រូវបានធ្វើឡើងក្នុងអំឡុងពេល ២៥ថ្ងៃ ចាប់ពីថ្ងៃទី២៥ ខែតុលា ដល់ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២៥។ ការអង្កេតនេះបានគ្របដណ្តប់លើគ្រួសារចំនួន ៩.៩១២គ្រួសារ ក្នុងភូមិចំនួន ៧០៨ភូមិ ដែលបានគ្របដណ្តបទូទាំងរាជធានីភ្នំពេញខេត្តចំនួន ២៥ ទូទាំងប្រទេស។ បញ្ជីសំណាកដែលបានប្រើ

ប្រាស់ គឺផ្អែកលើជំរឿនទូទៅប្រជាជនកម្ពុជា ឆ្នាំ២០១៩។ ការរៀបចំផែនការសំណាក ការបណ្តុះបណ្តាលយ៉ាងហ្មត់ចត់ ការធ្វើតេស្តសាកល្បង និងការគ្រប់គ្រងការចុះប្រមូលទិន្នន័យផ្ទាល់ បានគាំទ្រដល់ការប៉ាន់ប្រមាណប្រកបដោយភាពជឿជាក់ទាំងក្នុងកម្រិតថ្នាក់ជាតិ និងកម្រិតតំបន់ទីប្រជុំជន ជនបទ។

លទ្ធផលបានបង្ហាញពីកម្រិតខ្ពស់នៃអត្រាចូលរួមក្នុងកម្លាំងពលកម្ម និងការមានការងារធ្វើ ព្រមជាមួយគ្នានឹងបញ្ហាប្រឈមជារចនាសម្ព័ន្ធដែលកំពុងកើតមាន ជាពិសេសពាក់ព័ន្ធនឹងការងារយុវជន គម្លាតយេនឌ័រ និងគុណភាពនៃការងារ។

យោងតាមច្បាប់ស្តីពីស្ថិតិ និងអនុក្រឹត្យស្តីពីស្ថិតិផ្លូវការដែលបានចាត់តាំង រាជរដ្ឋាភិបាលកម្ពុជាបានតម្រូវអោយវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ ប្រកាសផ្សព្វផ្សាយជាសាធារណៈនូវស្ថិតិអង្កេតកម្លាំងពលកម្មប្រចាំឆ្នាំ។ គោលបំណងសំខាន់គឺឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកប្រើប្រាស់ទិន្នន័យដែលមានដូចជា រាជរដ្ឋាភិបាលកម្ពុជា អង្គការជាតិ និងអន្តរជាតិ អង្គការមិនមែនរដ្ឋាភិបាល អ្នកស្រាវជ្រាវ អ្នកធ្វើផែនការ និងអ្នកធ្វើគោលនយោបាយ និងដើម្បីបង្កើនប្រសិទ្ធភាពក្នុងការអភិវឌ្ឍគោលនយោបាយ អភិវឌ្ឍន៍ជាតិ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ និងការខិតខំដើម្បីសម្រេចបានគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា។

អ្វីដែលពិសេសនោះ គឺការចង់បានទិន្នន័យឆ្លុះបញ្ចាំងដល់ការគាំទ្រនៃយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី ១ របស់រាជរដ្ឋាភិបាលកម្ពុជាសម្រាប់នីតិកាលទី ៧ នៃរដ្ឋសភា និងបម្រើតម្រូវការសម្រាប់គោលនយោបាយទីផ្សារការងារ។ ក្រសួងផែនការ ជាពិសេសវិទ្យាស្ថានជាតិស្ថិតិជាអ្នកគ្រប់គ្រងការផ្តល់ទិន្នន័យស្ថិតិផ្លូវការ ហើយក៏នឹងផ្តល់អាទិភាពដល់កិច្ចខិតខំប្រឹងប្រែងដើម្បីធ្វើឱ្យប្រសើរឡើងនូវការសម្របសម្រួលរវាងអ្នកផលិត និងអ្នកប្រើប្រាស់ទិន្នន័យសូចនាករ ដើម្បីធានាថាតម្រូវការត្រូវបានឆ្លើយតប។

ការអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ គឺផ្អែកលើគំរូអង្កេតកម្លាំងពលកម្មរបស់ ILO ដែលរួមមានសំណួរលម្អិតអំពីចរិតលក្ខណៈនៃម៉ូឌុលប្រជាសាស្ត្រ និងកម្លាំងពលកម្ម ស្ថានភាពចំណាកស្រុកអន្តរជាតិ ការងារថែទាំដែលមិនបានទទួលប្រាក់ឈ្នួល ភាពមិនត្រូវគ្នានៃជំនាញ និងគុណវុឌ្ឍិ។ អង្កេតបានប្រមូលព័ត៌មានជាច្រើនដែលអាចប្រើសម្រាប់ការរៀបចំ ការអនុវត្ត ការតាមដាន និង ការវាយតម្លៃគោលនយោបាយ និងកម្មវិធីការងារ និងកម្លាំងពលកម្មនានានៅទូទាំងប្រទេស។

## ១.២ គោលដៅនៃការអង្កេត

គោលដៅចម្បងនៃការអង្កេតគឺដើម្បីប្រមូលទិន្នន័យដ៏ទូលំទូលាយលើសកម្មភាពសេដ្ឋកិច្ចសម្រាប់ប្រជាជនដែលមានអាយុ១៥ឆ្នាំឡើង។ នេះរួមបញ្ចូលទាំងការតាមដាននិន្នាការកម្លាំងពលកម្មដូចជា ភាពមានការងារធ្វើ ភាពអត់ការងារធ្វើ និងភាពអសកម្មនៃកម្លាំងពលកម្ម។ ការរកឃើញនេះផ្តល់នូវមូលដ្ឋានគ្រឹះដែលមានមូលដ្ឋានលើភស្តុតាងសម្រាប់ភ្នាក់ងាររដ្ឋាភិបាល អង្គការអន្តរជាតិ និងអ្នកស្រាវជ្រាវដើម្បីរៀបចំការអន្តរាគមន៍សម្រាប់គោលដៅ។ លើសពីនេះ ការអង្កេតនេះតម្រឹមទិន្នន័យជាតិជាមួយនឹងស្តង់

ជាអន្តរជាតិសម្រាប់ស្ថិតិការងារ និងការប្រើប្រាស់កម្លាំងពលកម្មមិនគ្រប់គ្រាន់។

ព័ត៌មានដែលប្រមូលបានតាមរយៈការអង្កេតកម្លាំងពលកម្ម ឆ្នាំ២០២៥ ជាជំនួយដល់អ្នកធ្វើគោលនយោបាយនិងសម្រាប់កម្មវិធីរបស់ថ្នាក់ដឹកនាំ នៅក្នុងការវាយតម្លៃកម្មវិធី និងយុទ្ធសាស្ត្រពង្រឹងសុខភាពប្រជាជនទូទាំងប្រទេសផងដែរ។ លើសពីនេះ ការអង្កេតកម្លាំងពលកម្ម ឆ្នាំ២០២៥ ក៏បានបំពេញនូវសូចនាករនៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពសកល(SDGs) ផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ (NSDP) យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ (PS1) របស់រាជរដ្ឋាភិបាលកម្ពុជា។

## ១.៣ ការសម្ងាត់

មាត្រា ៣០ នៃច្បាប់ស្តីពីស្ថិតិបានបង្ហាញការរក្សាការសម្ងាត់។ មាត្រានេះបានចែងយ៉ាងច្បាស់ថាមន្ត្រីរាជការ បុគ្គលិកធ្វើការនៅវិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការ និងអង្គភាពស្ថិតិក្នុងក្រសួង ស្ថាប័នរាជរដ្ឋាភិបាល ក៏ដូចជាមន្ត្រីស្ថិតិដែលបានចាត់តាំងដោយអង្គការទាំងនោះ ត្រូវធានារក្សាការសម្ងាត់នូវរាល់ព័ត៌មានផ្ទាល់ខ្លួនទាំងឡាយដែល បានមកពីអ្នកឆ្លើយ។ ព័ត៌មានដែលប្រមូលបានក្រោមច្បាប់នេះ ត្រូវយកមកប្រើប្រាស់តែក្នុងគោលដៅស្ថិតិប៉ុណ្ណោះ។

មាត្រានេះត្រូវបានដាក់បញ្ចូលក្នុងច្បាប់ ជាពិសេសដើម្បីធានារក្សាការសម្ងាត់ទិន្នន័យផ្ទាល់ខ្លួនដែលងាយរំភើប ឬឈឺចាប់ ហើយក៏ចាំបាច់ណាស់ក្នុងការទទួលបានការទុកចិត្តពីអ្នកផ្តល់ទិន្នន័យ។ បើអ្នកឆ្លើយមិនជឿថាព័ត៌មាន ផ្ទាល់ខ្លួនរបស់ពួកគេនឹងត្រូវបានរក្សាទុកជាការសម្ងាត់ និងមិនត្រូវបានចែករំលែកដល់ស្ថាប័នរាជរដ្ឋាភិបាលដទៃទៀត (ឧទាហរណ៍ នាយកដ្ឋានពន្ធដារ) ពួកគេនឹងមិនផ្តល់នូវព័ត៌មានពិតឬពួកគេនឹងបដិសេធផ្តល់ព័ត៌មានណាមួយទាល់តែសោះ ហើយជាលទ្ធផលមានអត្រាឆ្លើយតបការអង្កេតដោយមានការជឿទុកចិត្តរបស់អ្នកឆ្លើយពិតជាមានសារៈសំខាន់ ដើម្បីធានាបាននូវអត្រាឆ្លើយខ្ពស់ និងប្រមូលបានទិន្នន័យមានគុណភាពល្អ។ មិនដាក់បញ្ចូលមាត្រានេះនឹងមានន័យថាបន្ថអត្រាឆ្លើយទាបនិងស្ថិតិមានគុណភាពទាប។

ម៉្យាងទៀត មាត្រា ៣៤ នៃច្បាប់ស្តីពីស្ថិតិចែងថា មន្ត្រីរាជការ និងមន្ត្រីស្ថិតិដែលបានចាត់តាំងដោយក្រសួងផែនការ និងដោយក្រសួង ស្ថាប័នរាជរដ្ឋាភិបាលដែលបានប្រព្រឹត្តល្មើសនឹងមាត្រា ៣០ នៃច្បាប់នេះនឹងត្រូវទទួលទណ្ឌកម្មរដ្ឋបាល។

មាត្រានេះមានសារៈសំខាន់ណាស់ដែលអាចធានាដល់អ្នកផ្តល់ទិន្នន័យថា ការដាក់ពិន័យជាក់លាក់នឹងអនុវត្តចំពោះមន្ត្រីរាជការ និងមន្ត្រីស្ថិតិដែលបានចាត់តាំងដែលបានរំលោភលើការសម្ងាត់ ឬប្រើព័ត៌មានផ្ទាល់ខ្លួនរបស់ពួកគេ មិនត្រឹមត្រូវ។

ក្នុងអំឡុងពេលបណ្តុះបណ្តាលអង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ ច្បាប់ស្តីពីស្ថិតិ ជាពិសេសជំពូកសិទ្ធិ និងកាតព្វកិច្ច និងជំពូកទោសប្បញ្ញត្តិត្រូវបានបង្ហាញដល់មន្ត្រីទាំងអស់ដែលបានចូលរួមក្នុងដំណើរការអង្កេតនេះ។

## ១.៤ ទស្សនាទាន និងនិយមន័យ

អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ បានអនុវត្តតាមស្តង់ដារអន្តរជាតិថ្មី ដែលបានអនុម័តដោយ សន្និសីទ អន្តរជាតិនៃអ្នកស្ថិតិកម្លាំងពលកម្មលើកទី១៩ នៅឆ្នាំ២០១៣។ សន្និសីទអន្តរជាតិនៃអ្នកស្ថិតិ កម្លាំងពលកម្មលើកទី១៩ បានដាក់ចេញនូវក្របខ័ណ្ឌថ្មីមួយសម្រាប់ស្ថិតិទីផ្សារការងារ រួមមានស្ថិតិ ទាក់ទងនឹងការងារ ភាពមានការងារធ្វើ និងការប្រើមិនគ្រប់គ្រាន់នូវកម្លាំងពលកម្ម។

និយមន័យនៃពាក្យ "ភាពមានការងារធ្វើ" ដែលប្រើក្នុងកម្លាំងពលកម្មកម្ពុជា គ្របដណ្តប់លើ សកម្មភាពស្ទើរតែទាំងអស់នៅក្នុងព្រំដែនផលិតកម្មប្រព័ន្ធគណនេយ្យជាតិ (SNA) រួមទាំងការផលិត សម្រាប់ប្រាក់បៀវត្សរ៍ ប្រាក់ចំណេញ ឬផលប្រយោជន៍គ្រួសារ និងការផលិតសម្រាប់ការប្រើប្រាស់ចុងក្រោយ ផ្ទាល់ខ្លួន។ ទោះជាយ៉ាងណាក៏ដោយ និយមន័យនៃភាពមានការងាររួមបញ្ចូលតែការងារដែលធ្វើឡើង សម្រាប់អ្នកដទៃទទួលបានប្រាក់បៀវត្សរ៍ ឬប្រាក់ចំណេញប៉ុណ្ណោះ។ ការផលិតសម្រាប់ការប្រើប្រាស់ចុង ក្រោយផ្ទាល់ខ្លួនមិនត្រូវបានចាត់ទុកថាជាភាពមានការងារធ្វើឡើយ។

## និយមន័យ

### អ្នកដែលមានការងារធ្វើ

អ្នកដែលមានការងារធ្វើគឺជាមនុស្សទាំងអស់ដែលមានអាយុធ្វើការ ក្នុងអំឡុងពេលយោងខ្លី (ប្រាំពីរថ្ងៃ ឬ មួយសប្តាហ៍) បានចូលរួមក្នុងសកម្មភាពណាមួយដើម្បីផលិតទំនិញ ឬផ្តល់សេវាកម្មជាថ្នូរនឹងប្រាក់ឈ្នួល ឬដើម្បីបង្កើតប្រាក់ចំណេញ។

**ពួកគេរួមមាន៖**

អ្នកដែលមានការងារធ្វើ "នៅកន្លែងធ្វើការ" ពោលគឺអ្នកដែលមានការងារធ្វើយ៉ាងហោចណាស់ មួយម៉ោងឡើងទៅ។ អ្នកដែលមានការងារធ្វើ "មិននៅកន្លែងធ្វើការ" ដោយសារតែអវត្តមានបណ្តោះ អាសន្នពីការងារ ឬការរៀបចំពេលវេលាធ្វើការ (ដូចជាការងារតាមវេន ម៉ោងធ្វើការបត់បែនតាមជាក់ស្តែង និងការឈប់សម្រាកសំណងដោយធ្វើការបន្ថែមម៉ោង)។

"សម្រាប់ប្រាក់ឈ្នួល ឬប្រាក់ចំណេញ" សំដៅទៅលើការងារដែលធ្វើឡើងដោយរំពឹងថានឹងទទួល បានប្រាក់បំណាច់ក្នុងទម្រង់ជាប្រាក់ឈ្នួល ឬប្រាក់ខែសម្រាប់ពេលវេលាធ្វើការ ឬការងារដែលបានធ្វើ ឬ ក្នុងទម្រង់ជាប្រាក់ចំណេញពីការលក់ ឬការដោះដូរទំនិញ និងសេវាកម្ម។ នេះរួមបញ្ចូលទាំងប្រាក់បំណាច់ ជាសាច់ប្រាក់ ឬជាវត្ថុ មិនថាបង់ដោយផ្ទាល់ទៅអ្នកដែលកំពុងធ្វើការ ឬដោយប្រយោលទៅគ្រួសារ ឬ សមាជិកគ្រួសារ(ដូចដែលអាចកើតឡើងនៅក្នុងអាជីវកម្មគ្រួសារ)។ ភាពខុសគ្នារវាងការងារ និងការផលិត ទំនិញប្រើប្រាស់ដោយខ្លួនឯងគឺផ្អែកលើគោលដៅសំខាន់នៃការផលិត។ ការផលិតទំនិញដែលភាគច្រើន មានបំណងលក់ ឬដោះដូរត្រូវបានរួមបញ្ចូលនៅក្នុងការងារ។

ប្រភព៖ សេចក្តីសម្រេចទី I ទាក់ទងនឹងស្ថិតិការងារ ភាពមានការងារធ្វើ និងការប្រើប្រាស់កម្លាំង ពលកម្មមិនគ្រប់គ្រាន់ ICLS លើកទី ១៩ (២០១៣)។

ខាងក្រោមនេះជានិយមន័យនៃទស្សនាទានដែលបានផ្តល់ដោយសន្និសីទអន្តរជាតិនៃអ្នកស្ថិតិកម្លាំងពលកម្ម (ICLS) លើកទី ១៩ ។

"**ប្រជាជនក្នុងអាយុធ្វើការ**" សំដៅលើមនុស្សទាំងអស់មានអាយុ១៥ ឆ្នាំឡើង។ ប្រជាជនក្នុងអាយុធ្វើការរួមមានអ្នក នៅក្នុងកម្លាំងពលកម្ម (អ្នកមានការងារធ្វើ ឬអ្នកគ្មានការងារធ្វើ) ក៏ដូចជាអ្នកនៅក្រៅកម្លាំងពលកម្ម។

បានចូលរួមក្នុងសកម្មភាពណាមួយ ដើម្បីផលិតទំនិញ ឬផ្តល់សេវាកម្មប្តូរយកប្រាក់ឈ្នួល ឬដើម្បីរកចំណេញ។ ពួកគេ រួមមានអ្នកមានការងារធ្វើ "នៅកន្លែងការងារ" (ពោលគឺអ្នកដែលបានធ្វើការយ៉ាងហោចណាស់មួយម៉ោង) និងអ្នកមានការងារធ្វើ "មិននៅកន្លែងការងារ" ដោយសារតែអវត្តមានជាបណ្តោះអាសន្នពីការងារ ឬដោយសារការរៀបចំពេលវេលាធ្វើការ (ដូចជា ការងារប្តូរវេន ការបញ្ចប់ការងារតាមពេលវេលាខុសៗគ្នា និងការឈប់សម្រាកសំណងដោយធ្វើការបន្ថែមម៉ោង)។

អ្នកមានការងារធ្វើ រួមមាន៖

- អ្នកធ្វើការដើម្បីប្រាក់ឈ្នួល ឬប្រាក់ចំណេញ ដែលកំពុងចូលរួមក្នុងសកម្មភាពបណ្តុះបណ្តាល ឬបង្កើនជំនាញដែលតម្រូវដោយការងារ ឬសម្រាប់ការងារផ្សេងទៀតនៅក្នុងអង្គភាពសេដ្ឋកិច្ចតែមួយ (អ្នកទាំងនេះត្រូវបានចាត់ទុកថាជាអ្នកមានការងារធ្វើ និង "នៅកន្លែងការងារ" ស្របតាមស្តង់ដារស្ថិតិអន្តរជាតិស្តីពីម៉ោងធ្វើការ)។
- អ្នករៀនធ្វើការ អ្នកហាត់ការ ឬអ្នកហាត់រៀន ដែលធ្វើការដើម្បីប្រាក់ឈ្នួលជាសាច់ប្រាក់ ឬជារបស់។
- អ្នកធ្វើការដើម្បីប្រាក់ឈ្នួល ឬចំណេញ តាមរយៈកម្មវិធីលើកកម្ពស់ការងារ។
- អ្នកធ្វើការនៅក្នុងអង្គភាពសេដ្ឋកិច្ចខ្លួនឯង ដើម្បីផលិតទំនិញក្នុងគោលបំណងចម្បងសម្រាប់លក់ ឬដោះដូរ ទោះបីផ្នែកខ្លះនៃផលិតផលត្រូវបានប្រើប្រាស់ដោយក្រុមគ្រួសារ ឬគ្រួសារក៏ដោយ។
- អ្នកមានការងារតាមរដូវក្នុងពេលបិទរដូវ បើពួកគេនៅបន្តបំពេញភារកិច្ច និងកិច្ចការមួយចំនួននៃការងារ ដោយ មិនរាប់បញ្ចូលការបំពេញកាតព្វកិច្ចផ្លូវច្បាប់ ឬរដ្ឋបាល (ឧទាហរណ៍ បង់ពន្ធ) និងមិនគិតការទទួលបានអត្ថ ប្រយោជន៍
- អ្នកធ្វើការដើម្បីប្រាក់ឈ្នួល ឬចំណេញ ដែលត្រូវបង់ឱ្យក្រុមគ្រួសារ ឬគ្រួសារ
    a) នៅក្នុងទីផ្សារប្រតិបត្តិការដោយសមាជិកគ្រួសាររស់នៅក្នុងគ្រួសារតែមួយ ឬក្នុងគ្រួសារផ្សេងទៀត
    b) បំពេញភារកិច្ច ឬកិច្ចការជានិយោជិតរបស់សមាជិកគ្រួសារនៅក្នុងគ្រួសារតែមួយ ឬក្នុងគ្រួសារផ្សេងទៀត
- ជាសមាជិកទៀងទាត់នៃកងកម្លាំងប្រដាប់អាវុធ និងអ្នកមានមុខងារជាយោធាឬជាស៊ីវិលជំនួស ដែលបំពេញ ការងារនេះដើម្បីប្រាក់ឈ្នួលជាសាច់ប្រាក់ ឬជារបស់។

អង្កេតកម្លាំងពលកម្ម បានចាត់ថ្នាក់ អ្នកនៅកន្លែងការងារ ជាអ្នកមានការងារធ្វើ កាលណាគាត់

ឬនាង បានធ្វើការ យ៉ាងហោចណាស់មួយម៉ោងក្នុងសប្តាហ៍យោង។

**"អ្នកគ្មានការងារធ្វើ"** សំដៅលើមនុស្សក្នុងអាយុធ្វើការងារទាំងអស់ ដែលមិនបានធ្វើការងារក្នុងរយៈពេលសប្តាហ៍យោង ប៉ុន្តែបានអនុវត្តសកម្មភាពស្វែងរកការងារធ្វើក្នុងរយៈពេលថ្មីៗជាក់លាក់ណាមួយ និងបច្ចុប្បន្នអាចទទួលយកការងារធ្វើបាន នៅពេលផ្តល់ឱកាសការងារឱ្យគាត់។

**អ្នកគ្មានការងារធ្វើ រួមមាន៖**

១. "មិនធ្វើការងារ"ត្រូវបានវាយតម្លៃដោយយោងទៅលើរយៈពេលយោងខ្លី សម្រាប់ការវាស់វែងការងារ

២. "បានស្វែងរកការងារធ្វើ" សំដៅលើសកម្មភាពណាមួយដែលបានអនុវត្ត ក្នុងរយៈពេលថ្មីៗ ជាក់លាក់ណាមួយ រួមមាន ៤ សប្តាហ៍ ឬមួយខែមុន សម្រាប់គោលបំណងរកការងារធ្វើ ឬបង្កើតអាជីវកម្ម ឬធ្វើកសិកម្ម។ ផ្នែកនេះក៏រាប់បញ្ចូលផងដែរនូវការងារក្រៅម៉ោង ការងារក្រៅប្រព័ន្ធ ការងារបណ្តោះអាសន្ន និងការងារតាមរដូវ ឬម្តងម្កាល ក្នុងប្រទេស ឬក្រៅប្រទេស។ ឧទាហរណ៍នៃសកម្មភាពទាំងនេះគឺ៖

២.១ ការរៀបចំធនធានហិរញ្ញវត្ថុ ដាក់ពាក្យសុំការអនុញ្ញាត អាជ្ញាប័ណ្ណ

២.២ ស្វែងរកដី ទីក្នុងបរិវេណ ម៉ាស៊ីន សម្ភារៈផ្គត់ផ្គង់ ឧបករណ៍កសិកម្ម

២.៣ ស្វែងរកជំនួយពីមិត្តភក្តិ សាច់ញាតិ ឬប្រភេទអន្តរការីផ្សេងទៀត

២.៤ ចុះឈ្មោះជាមួយ ឬទាក់ទងសេវាកម្មការងារសាធារណៈ ឬឯកជន

២.៥ ដាក់ពាក្យសុំដោយផ្ទាល់ដល់និយោជក ពិនិត្យកន្លែងធ្វើការ កសិដ្ឋាន ច្រកទ្វាររោងចក្រ ទីផ្សារ ឬ កន្លែងជួបប្រជុំផ្សេងទៀត

២.៦ ដាក់ពាក្យ ឬព័ត៌មានតាមកាសែត ឬការផ្សព្វផ្សាយការងារតាមអនឡាញ

២.៧ ដាក់ពាក្យ ឬធ្វើបច្ចុប្បន្នកម្មប្រវត្តិ អំពីវិជ្ជាជីវៈ ឬគេហទំព័របណ្តាញសង្គមតាមអនឡាន

៣. ចំណុចដែលសហគ្រាសចាប់ផ្តើមគួរតែត្រូវបានប្រើ ដើម្បីដឹងនូវភាពផ្សេងគ្នារវាងសកម្មភាពស្វែងរកក្នុងគោលដៅបង្កើតអាជីវកម្ម និងសកម្មភាពការងាររបស់ខ្លួនឯងផ្ទាល់ ។ ដែលបង្ហាញភស្តុតាងតាមការចុះឈ្មោះសហគ្រាសដើម្បីប្រតិបត្តិការ ឬនៅពេលមានធនធានហិរញ្ញវត្ថុ មានហេដ្ឋារចនាសម្ព័ន្ធ ឬសម្ភារៈចាំបាច់នៅនឹងកន្លែង ឬបានទទួលអតិថិជន ឬការបញ្ជាទិញដំបូង អាស្រ័យលើស្ថានភាពជាក់ស្តែង។

៤. "បច្ចុប្បន្នអាចធ្វើការបាន" ចង់ដឹងពីការត្រៀមខ្លួនជាស្រេច ដើម្បីចាប់ផ្តើមការងារក្នុងពេលបច្ចុប្បន្ន ដែលវាយតម្លៃដោយរយៈពេលយោងខ្លីមួយប្រើសម្រាប់វាស់វែងការងារ៖ អាស្រ័យលើកាលៈទេសៈជាតិ យោងតាមពេលវេលាអាចត្រូវបានពង្រីកដើម្បីរួមបញ្ចូលរយៈពេលខ្លីជាបន្តបន្ទាប់ដែលមិនលើសពីពីរសប្តាហ៍ ដើម្បីធានាបាននូវការគ្របដណ្តប់គ្រប់គ្រាន់នៃស្ថានភាពអត់ការងារធ្វើក្នុងចំណោមក្រុមប្រជាជនផ្សេងៗគ្នា។

**ភាពគ្មានការងារធ្វើរួមមាន ៖**

៤.១. អ្នកចាប់ផ្តើមនាពេលអនាគតបានកំណត់ជាមនុស្ស "មិនមានការងារធ្វើ" និង "បច្ចុប្បន្នអាចធ្វើការបាន" ដែលមិនបាន "ស្វែងរកការងារធ្វើ" ពីព្រោះពួកគេបានរៀបចំរួចហើយ ដើម្បីចាប់ផ្តើមការងារក្នុងរយៈពេលយោងខ្លីមួយ ដោយកំណត់លើរយៈពេលរង់ចាំជាទូទៅសម្រាប់ការចាប់ផ្តើមការងារថ្មីនៅក្នុងបរិបទប្រទេស ប៉ុន្តែជាទូទៅមិនច្រើនជាងបីខែ។

៤.២ អ្នកចូលរួមក្នុងការបណ្តុះបណ្តាលជំនាញ ឬគម្រោងបណ្តុះបណ្តាលឡើងវិញក្នុងកម្មវិធីលើកកម្ពស់ការងារ ដោយផ្អែកលើមូលដ្ឋាន "មិនមានការងារធ្វើ" និងមិន "បច្ចុប្បន្នអាចធ្វើការបាន" និងមិនបាន "ស្វែងរកការងារធ្វើ" ពីព្រោះពួក គេមានការងារដែលផ្តល់ឱ្យដែលត្រូវចាប់ផ្តើមក្នុងរយៈពេលបន្តបន្ទាប់ខ្លីមួយ ជាទូទៅមិនច្រើនជាងបីខែ។

៤.៣ អ្នក "មិនធ្វើការងារ" ដែលបានអនុវត្តសកម្មភាពចំណាកស្រុកទៅបរទេស ដើម្បីធ្វើការយកប្រាក់ឈ្នួល ឬចំណេញ ប៉ុន្តែពួកគេនៅរង់ចាំឱកាសចាកចេញ។

"**កម្លាំងពលកម្ម**" សំដៅលើមនុស្សក្នុងអាយុធ្វើការទាំងអស់ ដែលចូលរួមចំណែក ឬអាចចូលរួមចំណែកក្នុងការផលិត ទំនិញ និងសេវាកម្មនៅក្នុងប្រទេស ដើម្បីយកប្រាក់ឈ្នួល ឬទទួលបានចំណេញ។ ពួកគេអាចជាអ្នកមានការងារធ្វើ ឬគ្មានការងារធ្វើ ក្នុងរយៈពេលមួយសប្តាហ៍យោងមុនអង្កេត។

អ្នកនៅក្រៅកម្លាំងពលកម្ម សំដៅលើមនុស្សក្នុងអាយុធ្វើការទាំងអស់ ដែលអត់ធ្វើការ ឬមិនធ្វើការងារក្នុងរយៈពេលយោងជាក់លាក់ ដោយសារៈ

១. ជាប់រៀននៅគ្រឹះស្ថានសិក្សាជាសិស្ស

២. ជាប់ភារកិច្ចគ្រួសារ ថែទាំសមាជិកគ្រួសារ ឬក្នុងសកម្មភាពផ្សេងៗជាមេផ្ទះ

៣. ចូលនិវត្តន៍ ឬចាស់ជរា

៤. មូលហេតុផ្សេងទៀត ដូចជាភាពទន់ខ្សោយ ឬពិការភាព ដែលអាចបញ្ជាក់បាន ឬ

៥. ជឿថាគ្មានការងារធ្វើ មិនចង់ធ្វើការ ឬមិនមានការចាប់ផ្តើមការងារក្នុងរយៈពេលខ្លី។

"**ស្ថានភាពភាពមានការងារធ្វើ**" សំដៅលើប្រភេទកិច្ចសន្យាការងារជាក់ស្តែង ឬមិនជាក់លាក់នៃការងាររវាងមនុស្ស និងមនុស្ស ឬអង្គការផ្សេងទៀត។ ស្ថានភាពរបស់បុគ្គលសកម្មសេដ្ឋកិច្ចត្រូវគោរពតាមការងាររបស់ខ្លួន (ពោលទោះបីគាត់ជានិយោជក អ្នកធ្វើការដោយទុនផ្ទាល់ខ្លួន និយោជិត ឬអ្នកធ្វើការឱ្យគ្រួសារមិនយកប្រាក់ឈ្នួល) ត្រូវបានកំណត់ដូចខាងក្រោមៈ

**និយោជិត** គឺជាមនុស្សម្នាក់ ដែលធ្វើការឱ្យនិយោជកសាធារណៈ ឬឯកជន ហើយទទួលសំណងជាប្រាក់ឈ្នួល បៀវត្សរ៍ កម្រៃជើងសារ ប្រាក់ទឹកតែ ប្រាក់តាមអត្រាការងារ ឬឱ្យជារបស់។ និយោជិតត្រូវបានបែងចែកជាៈ

១. និយោជិតមានប្រាក់ឈ្នួលទៀងទាត់ ជាមួយប្រាក់ឈ្នួលថេរ

២. និយោជិតមានប្រាក់ឈ្នួលមិនទៀងទាត់/បណ្តោះអាសន្ន

៣. អ្នកធ្វើការមានប្រាក់ឈ្នួលតាមអត្រាការងារ ឬតាមការងារដែលបានបំពេញ និង

៤. អ្នករៀនធ្វើការមានប្រាក់ឈ្នួលមិនមែនគ្រួសារ។

**និយោជក** គឺជាមនុស្សម្នាក់ដែលក្នុងរយៈពេលយោងបានធ្វើការដោយទុនផ្ទាល់ខ្លួនរបស់គាត់ ឬជាមួយដៃគូម្នាក់ ឬច្រើននាក់នៅក្នុង "ការងារធ្វើដោយខ្លួនឯង" ជាមួយនិយោជិតម្នាក់ ឬច្រើននាក់ចូលរួមការងារជាប្រចាំជាមូលដ្ឋាន។

**អ្នកធ្វើការដោយទុនផ្ទាល់ខ្លួន** គឺជាមនុស្សម្នាក់ ដែលក្នុងរយៈពេលយោង បានធ្វើការដោយទុនផ្ទាល់ខ្លួនរបស់ពួកគេជាមួយដៃគូម្នាក់ ឬច្រើននាក់នៅក្នុង "ការងារធ្វើដោយខ្លួនឯង" ដោយគ្មាននិយោជិតណាមួយចូលរួមការងារជាប្រចាំ ប៉ុន្តែក៏អាចជាមួយអ្នកធ្វើការឱ្យគ្រួសារមិនយកប្រាក់ឈ្នួលម្នាក់ ឬច្រើននាក់ចូលរួមការងារម្តងម្កាលជាមូលដ្ឋានផងដែរ។ អ្នកធ្វើការប្រភេទនេះ រួមមានម្ចាស់អ្នកដាំដុះ អ្នកដាំដំណាំចែកគ្នា និងអ្នកដាំដុះ កិច្ចសន្យាធ្វើការដើម្បីចំណេញ។

**អ្នកធ្វើការឱ្យគ្រួសារមិនយកប្រាក់ឈ្នួល** គឺជាមនុស្សម្នាក់ដែលធ្វើការដោយគ្មានប្រាក់ឈ្នួលជាសាច់ប្រាក់ ឬជារបស់ ក្នុងសហគ្រាសមួយដែលប្រតិបត្តិការដោយសមាជិកក្រុមគ្រួសាររបស់គាត់ ឬដោយសមាជិកគ្រួសារមួយ។

**"ផ្សេងទៀត"** រួមមានសមាជិកនៃសហករណ៍អ្នកផលិត ។ល។

**វិស័យក្នុងប្រព័ន្ធ** រួមមានអ្នកធ្វើការទាំងអស់នៅក្នុងរដ្ឋាភិបាល ឬសហគ្រាសរដ្ឋ ឬអង្គការអន្តរជាតិ និងក្នុងស្ថានទូតបរទេស ក៏ដូចជាក្រុមហ៊ុនមានដែនកំណត់ភាពជាដៃគូពាណិជ្ជកម្ម ភាពជាដៃគូមានកំណត់ និងសហគ្រាសបានចុះបញ្ជីជាមួយអាជ្ញាធរពាក់ព័ន្ធ និង/ឬ មានបញ្ជីគណនេយ្យពេញលេញសម្រាប់រាយការណ៍ទៅរដ្ឋាភិបាល រួមមាន តារាងតុល្យភាពត្រឹមត្រូវមួយនៃទ្រព្យសម្បត្តិ ចំណូល និងចំណាយ។

**វិស័យក្រៅប្រព័ន្ធ** រួមមានអ្នកធ្វើការទាំងអស់នៅក្នុងសហគ្រាសដែលមិនបានចុះបញ្ជីជាមួយអាជ្ញាធរពាក់ព័ន្ធ និងគ្មានបញ្ជីគណនេយ្យពេញលេញ។ វិស័យក្រៅប្រព័ន្ធមិនរាប់បញ្ចូលគ្រួសារដែលផលិតសម្រាប់តែការប្រើប្រាស់ចុងក្រោយ ខ្លួនឯង កសិកម្មសម្រាប់ចិញ្ចឹមជីវិត ការសាងសង់លំនៅដ្ឋានខ្លួនឯង។ល។

**គ្រួសារ** រួមមានអ្នកធ្វើការទាំងអស់នៅក្នុងសហគ្រាសគ្រួសារដែលផលិតទំនិញ និងសេវាកម្មសម្រាប់តែការប្រើប្រាស់ ចុងក្រោយខ្លួនឯង។ គ្រួសារ រួមមានអ្នកធ្វើកិច្ចការផ្ទះមានប្រាក់ឈ្នួលជួលដោយគ្រួសារ។ បុគ្គលដែលបានចាត់ចូលក្នុង ផ្នែក៩៧ នៃចំណាត់ថ្នាក់សកម្មភាពសេដ្ឋកិច្ចតាមស្តង់ដារអន្តរជាតិ ជំនាន់៤ (ISIC) និងផ្នែក៦៣ នៃចំណាត់ថ្នាក់មុខរបរតាមស្តង់ដារអន្តរជាតិ ឆ្នាំ២០០៨ (ISCO-08) ត្រូវបានរាប់បញ្ចូលក្នុងវិស័យនេះ។

**ការងារក្នុងប្រព័ន្ធ** រួមមានអ្នកដែលធ្វើការនៅក្នុងអាជីវកម្មផ្ទាល់ខ្លួនរបស់ពួកគេក្នុងវិស័យក្នុងប្រព័ន្ធ ឬអ្នកធ្វើការជានិយោជិត អ្នករៀនធ្វើការ អ្នកហាត់ការរបស់និយោជកដែលចូលរួមវិភាគទានដល់របបសោធននិវត្តន៍ សុខភាព និង/ឬ មូលនិធិធានារ៉ាប់រងភាពគ្មានការងារធ្វើ ឬផ្តល់ប្រាក់ឈ្នួលឈប់សម្រាកប្រចាំឆ្នាំ

និងឈប់សម្រាកឈឺក្នុងករណីមាន ជំងឺ ឬរបួស។

**ការងារក្រៅប្រព័ន្ធ** រួមមាននិយោជក និងអ្នកធ្វើការដោយទុនផ្ទាល់ខ្លួនដែលធ្វើការក្នុងសហគ្រាសវិស័យក្រៅប្រព័ន្ធផ្ទាល់ខ្លួនរបស់ពួកគេ អ្នកធ្វើការឱ្យគ្រួសារមិនយកប្រាក់ឈ្នួល និងនិយោជិតនិងអ្នករៀនធ្វើការ និងអ្នកហាត់ការដែលគ្មានប្រាក់ឈ្នួលពេលឈប់សម្រាកប្រចាំឆ្នាំ ឬអត្ថប្រយោជន៍ឈប់សម្រាកឈឺ និងដែលនិយោជករបស់ពួកគេមិនបានចូលរួមវិភាគទានដល់របបសន្តិសុខសង្គមរបស់ពួកគេ។ ចំនួនមនុស្សក្នុងផ្នែកនេះ ជាផលសងរវាងចំនួនមនុស្សទាំងអស់ដែលបានធ្វើការ និងចំនួនមនុស្សក្នុងការងារក្នុងប្រព័ន្ធ។

**ភាពមានការងារធ្វើមិនគ្រប់គ្រាន់ទាក់ទងនឹងពេលវេលា** សំដៅលើមនុស្សទាំងអស់ក្នុងការងារ ដែលក្នុងរយៈពេលយោងខ្លី ចង់ធ្វើការម៉ោងបន្ថែម ដោយសារចំនួនម៉ោងធ្វើការក្នុងការងារទាំងអស់របស់គាត់តិចជាងកម្រិតម៉ោងដែលបានកំណត់ (៤០ ម៉ោងសម្រាប់កម្ពុជា)ហើយគាត់អាចធ្វើការម៉ោងបន្ថែមបានបើផ្តល់ឱកាសការងារមានប្រាក់ ឈ្នួលបន្ថែមទៀត ដែល៖

១. "ម៉ោងធ្វើការ" សំដៅលើចំនួនម៉ោងជាក់ស្តែងបានធ្វើការ ឬចំនួនម៉ោងធម្មតាបានធ្វើការអាស្រ័យលើគោលដៅនៃការវាស់វែង(ស្ថានភាពរយៈពេលខ្លី ឬវែង)និងអនុលោមតាមស្តង់ដារស្ថិតិអន្តរជាតិស្តីពីប្រធានបទ

២."ម៉ោងបន្ថែម" អាចជាម៉ោងលើសនៅក្នុងការងារតែមួយ នៅក្នុងមួយឬច្រើនការងារបន្ថែម ឬនៅក្នុងមួយឬច្រើនការងារជំនួស

៣."កម្រិតកំណត់ចំនួនម៉ោង" គឺផ្អែកលើព្រំដែនរវាងការងារម៉ោងពេញ និងម៉ោងក្រៅ លើតម្លៃមេដ្យាន ឬម៉ូតនៃ ចំនួនម៉ោងធ្វើការធម្មតារបស់អ្នកធ្វើការងារទាំងអស់ ឬលើបទដ្ឋានចំនួនម៉ោងធ្វើការដូចមានចែងក្នុងច្បាប់ពាក់ព័ន្ធ ឬការអនុវត្តថ្នាក់ជាតិ និងការកំណត់សម្រាប់ក្រុមអ្នកធ្វើការជាក់លាក់ និង

៤."អាចធ្វើការងារម៉ោងបន្ថែម" ត្រូវបានកំណត់ក្នុងរយៈពេលយោងខ្លីមួយ ដែលឆ្លុះបញ្ចាំងពីរយៈពេលតាមតម្រូវការនៅក្នុងបរិបទប្រទេសរវាងការចាកចេញពីការងារមួយ និងការចាប់ផ្តើមការងារផ្សេងទៀត។

**កម្លាំងពលកម្មសក្តានុពល** (អ្នកចូលរួម) សំដៅលើមនុស្សក្នុងអាយុធ្វើការទាំងអស់ ដែលក្នុងរយៈពេលយោង ខ្លី មិនបានធ្វើការងារ ឬគ្មានការងារធ្វើ ហើយ៖

១. ធ្វើសកម្មភាព "ស្វែងរកការងារធ្វើ" ហើយមិន "បច្ចុប្បន្នអាចធ្វើការបាន" ប៉ុន្តែនឹងអាចធ្វើបានក្នុងរយៈពេលបន្តបន្ទាប់ខ្លីមួយ ទៅតាមកាលៈទេសៈប្រទេស (ពោលគឺអ្នកស្វែងរកការងារតែមិនអាចធ្វើបាន) ឬ

២. មិនធ្វើសកម្មភាព "ស្វែងរកការងារធ្វើ ប៉ុន្តែចង់ធ្វើការ និង "បច្ចុប្បន្នអាចធ្វើការបាន" (ពោលគឺអ្នកស្វែងរក ការងារមានសក្តានុពលដែលអាចធ្វើបាន)។

# ជំពូក ២

## វិធីសាស្ត្រអង្កេត

ជំពូកនេះពិពណ៌នាអំពីវិធីសាស្ត្រដែលប្រើក្នុងការអង្កេតកម្លាំងពលកម្ម ឆ្នាំ២០២៥។ វាត្រូវបានពន្យល់អំពីវិសាលភាព និងការគ្របដណ្តប់នៃការអង្កេត ការរៀបចំជ្រើសរើសសំណាកគំរូ ប្រតិបត្តិការនៅមូលដ្ឋាន និងប្រព្រឹត្តកម្មទិន្នន័យ។ ការអង្កេតនេះត្រូវបានអនុវត្តន៍ក្នុងរយៈពេល ២៥ថ្ងៃ ត្រូវចាប់ផ្តើមពីថ្ងៃទី២៥ខែតុលា ដល់ថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២៥។

### ២.១. ទំហំ និងវិសាលភាព

ការអង្កេតកម្លាំងពលកម្ម ឆ្នាំ២០២៥ ត្រូវបានដំណើរការ ដើម្បីផ្តល់នូវការប៉ាន់ស្មានដែលអាចមានភាពជឿជាក់បាននូវចំនួនកម្លាំងពលកម្មកម្រិតថ្នាក់ជាតិនៅកម្ពុជា ទីប្រជុំជន និងជនបទ។ ការអង្កេតបានផ្តោតលើចំនួនប្រជាជនដែលមានអាយុធ្វើការ ដែលត្រូវបានកំណត់ថាជាអ្នកដែលមានអាយុ ១៥ ឆ្នាំឡើងទៅ ដែលកំពុងរស់នៅក្នុងគ្រួសារគំរូ។ អង្កេតបានរៀបចំឡើងដើម្បីទទួលបានការប៉ាន់ស្មានថ្នាក់ជាតិនៃអថេរជាច្រើន ជាពិសេសទាក់ទងនឹងសកម្មភាពសេដ្ឋកិច្ច និងមិនមែនសេដ្ឋកិច្ចរបស់ប្រជាជនកម្ពុជានៅក្នុងកម្លាំងពលកម្ម។

ការអង្កេតនេះពាក់ព័ន្ធនឹងគំរូចំនួន ៩.៩១២ គ្រួសារ ពី ៧០៨ ភូមិសំណាកគំរូ ដោយបែងចែកនៅ២៥រាជធានីភ្នំពេញ ខេត្ត។ ការអង្កេតនេះគ្របដណ្តប់ទាំងតំបន់ទីប្រជុំជន និងទីជនបទ និងគ្រប់ប្រភេទទាំងអស់នៃគ្រួសារធម្មតា រួមទាំងគ្រួសារដែលមានមនុស្សម្នាក់ផងដែរ។

### ២.២. បញ្ជីសំណួរ

បញ្ជីសំណួរអង្កេតកម្លាំងពលកម្ម ឆ្នាំ២០២៥ ត្រូវបានបង្កើតឡើងដោយផ្អែកលើ "សេចក្តីសម្រេចស្តីពីស្ថិតិការងារ ភាពមានការងារធ្វើ និងការប្រើប្រាស់កម្លាំងពលកម្មមិនគ្រប់គ្រាន់" ដែលត្រូវបានអនុម័តដោយសន្និសីទអន្តរជាតិលើកទី១៩ ទី២០ និងទី២១ នៃអ្នកស្ថិតិការងារ (ICLS)។ នៅឆ្នាំ២០២៤ កម្រងសំណួរបានបញ្ចូលម៉ូឌុលចំនួនបីពីការអង្កេតកម្លាំងពលកម្មគំរូរបស់ ILO ដែលត្រូវបានរៀបចំឡើងសម្រាប់ការប្រមូលទិន្នន័យការសម្ភាសន៍ផ្ទាល់ខ្លួនដោយមានជំនួយពីកុំព្យូទ័រ (CAPI) ដែលមាន ១៧ ផ្នែកដូចខាងក្រោម៖

១. ផ្នែក A. បញ្ជីសមាជិកគ្រួសារ និងលក្ខណៈប្រជាសាស្ត្រ (DEM)
២. ផ្នែក B. ស្ថានភាពទេសន្តរប្រវេសន៍អន្តរជាតិ (MIG)
៣. ផ្នែក C. ស្ថានភាពពិការភាព (DIF)
៤. ផ្នែក D. ប្រភពរបស់គ្រួសារក្នុងការចិញ្ចឹមជីវិត (HLL)
៥. ផ្នែក E. ស្ថានភាពអ្នកផ្តល់ចម្លើយ (RSP)

៦. ផ្នែក F. ភាពមានការងារធ្វើ (ATW)
៧. ផ្នែក G. អវត្តមានពីការងារបណ្ដោះអាសន្ន (ABS)
៨. ផ្នែក H. ការងារកសិកម្ម និងការលក់ផលិតផលកសិកម្ម (AGF)
៩. ផ្នែក I. ការងារចម្បង - ចរិតលក្ខណៈនៃការងារចម្បង (MJJ)
១០. ផ្នែក J : ការងារទីពីរ - ចរិតលក្ខណៈនៃការងារ (SJJ)
១១. ផ្នែក K. ម៉ោងធ្វើការក្នុងការងារ (WKT)
១២. ផ្នែក L ៖ ការស្វែងរកការងារ និងភាពអាចមានលទ្ធភាពធ្វើការ (SRH)
១៣. ផ្នែក M. ការដាំដំណាំសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន (OPC)
១៤. ផ្នែក N. ផលិតផលសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួននៃម្ហូបអាហារមិនមែនចេញពីផលដំណាំ (OPC)
១៥. ផ្នែក O. ផលិតផលសម្រាប់ប្រើប្រាស់ផ្ទាល់ខ្លួន-សំណង់ (BLDG)
១៦. ផ្នែក P. ការងារផ្ទះដែលមិនមានប្រាក់កម្រៃ (UCW)
១៧. ផ្នែក Q. ភាពមិនស៊ីគ្នានៃជំនាញ និងគុណវុឌ្ឍិ (SQM)

## ២.៣. វិធីសាស្ត្រជ្រើសរើសសំណាកគំរូ

ដើម្បីសម្រេចបាននូវគោលដៅនៃការផ្តល់ការប៉ាន់ស្មានដែលអាចទុកចិត្តបាននៅកម្រិតជាតិ ទីប្រជុំជន និង ជនបទ អង្កេតកម្លាំងពលកម្ម ឆ្នាំ២០២៥ បានប្រើវិធីសាស្ត្រជ្រើសរើសគំរូតាមដំណាក់កាលបីដំណាក់កាល៖ (i) ការជ្រើសរើសភូមិ (ii) ការជ្រើសរើសមណ្ឌលសម្ភាសន៍មួយ សម្រាប់ភូមិសំណាកគំរូនីមួយៗនិង (iii) ការជ្រើសរើសគ្រួសារសម្រាប់មណ្ឌលសម្ភាសន៍នីមួយៗសំណាកគំរូនីមួយៗ។ តំបន់ទីប្រជុំជន និង តំបន់ជនបទត្រូវបានបម្រើជាអថេរតាមផ្នែក។

ឯកតាសំណាកគំរូបឋម (PSU) គឺជាភូមិ។ ភូមិត្រូវបានជ្រើសជាសំណាកគំរូ តាមប្រូបាប៊ីលីតេសមាមាត្រទៅនឹងចំនួនគ្រួសារដែលបានចុះបញ្ជីនៅក្នុងក្របខ័ណ្ឌ។

មណ្ឌលសម្ភាសន៍ (EA) គឺជាផ្នែកមួយនៃភូមិមួយ ហើយផ្នែកមួយនេះត្រូវបានជ្រើសរើសដោយចៃដន្យពីក្នុងភូមិនីមួយៗ ដែលជាសំណាកគំរូ។

ឯកតាជ្រើសសំណាកគំរូចុងក្រោយ គឺគ្រួសារ ជាសរុបចំនួន ១៤ គ្រួសារ ត្រូវបានជ្រើសរើសដោយចៃដន្យតាមវិធីសាស្ត្រជ្រើសសំណាកគំរូតាមប្រព័ន្ធ ពីក្នុងមណ្ឌលសម្ភាសន៍នីមួយៗ។

## ២.៤. ក្របខ័ណ្ឌជ្រើសសំណាកគំរូ

ក្របខ័ណ្ឌជ្រើសសំណាកគំរូប្រើសម្រាប់អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ ត្រូវបានរៀបចំដោយវិទ្យាស្ថានជាតិស្ថិតិ ដោយប្រើព័ត៌មានដែលបានប្រមូលពីជំរឿនទូទៅប្រជាជននៅកម្ពុជា ឆ្នាំ២០១៩។ ក្របខ័ណ្ឌមានចំនួន ១៤.៥១៤ ភូមិ បានបែងចែកក្នុងចំណោម ៧០៨ (PSU) ឯកតាសំណាកគំរូបឋម និង ៧០៨ មណ្ឌលសម្ភាសន៍នៅទូទាំងប្រទេស។ មុនធ្វើជំរឿនទូទៅប្រជាជននៅកម្ពុជា ឆ្នាំ២០១៩ ផែនទីព្រាងត្រូវបានរៀបចំដើម្បីកំណត់ព្រំប្រទល់នៃមណ្ឌលសម្ភាសន៍នីមួយៗ។ ផែនទីនេះក៏ត្រូវបានប្រើប្រាស់

សម្រាប់អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥ ផងដែរ។

## ២.៥. សមាមាត្រទម្ងន់សំណាកគំរូ

**ជំហានដំបូង** សមាមាត្រទម្ងន់ (weight) សម្រាប់ឯកតាសំណាកគំរូបឋមដែលបានជ្រើសរើស (១) ក្នុងតំបន់ h (ទីប្រជុំជន/ជនបទ) ត្រូវបានគណនាតាមរូបមន្តខាងក្រោម៖

$$W_{I,hi} = \frac{M_h}{n_h \cdot M_{hi}}$$

$M_h$ = ចំនួនគ្រួសារក្នុងតំបន់ (h) យោងតាមការចុះបញ្ជីភូមិ

$M_{hi}$ = ចំនួនគ្រួសារក្នុងឯកតាសំណាកគំរូបឋម (1) ក្នុងតំបន់ (h) យោងតាមការចុះបញ្ជីភូមិ

$n_h$ = ចំនួនឯកតាសំណាកគំរូបឋមដែលបានជ្រើសរើសក្នុងតំបន់ (h)

**ជំហានទីពីរ** សមាមាត្រទម្ងន់សម្រាប់គ្រួសារដែលបានជ្រើសរើស ក្នុងឯកតាសំណាកគំរូបឋមដែលបានជ្រើសរើស ត្រូវបានគណនាតាមរូបមន្តខាងក្រោម៖

$$W_{II,hi} = \frac{M^*_{hi}}{m_{hik}}$$

M = ចំនួនគ្រួសារក្នុងឯកតាសំណាកគំរូបឋម (1) នៃតំបន់ (h) នៅពេលអង្កេត

$m_{hik}$ = ចំនួន ១៤ គ្រួសារសំណាកគំរូ ក្នុងមួយឯកតាសំណាកគំរូ (1) ក្នុងតំបន់ (h)

$M^*$ ត្រូវបានកំណត់ជាពីរវិធីសាស្ត្រផ្សេងគ្នា អាស្រ័យលើស្ថានភាព។ បើឯកតាសំណាកគំរូបឋមដែលបានជ្រើសរើសមានតែមួយមណ្ឌលសម្ភាសន៍ នោះការចុះបញ្ជីគ្រួសារនៅក្នុងមណ្ឌលសម្ភាសន៍នឹងចុះគ្រប់គ្រួសារទាំងអស់ដែលមាននៅក្នុងឯកតាសំណាកគំរូបឋម។ បើឯកតាសំណាកគំរូបឋមនៅក្នុងមណ្ឌលសម្ភាសន៍ច្រើន នោះការចុះបញ្ជីគ្រួសារត្រូវចុះបញ្ជីតែចំនួនគ្រួសារនៅក្នុងមណ្ឌលសម្ភាសន៍ដែលបានជ្រើសរើសប៉ុណ្ណោះ។ ក្នុងករណីនេះ ចំនួនគ្រួសារនៅក្នុងឯកតាសំណាកគំរូបឋម ត្រូវបានទទួលពីប្រធានភូមិ។

M ច្រើនតែខុសពី Mhi ដែលជាចំនួនគ្រួសារក្នុងឯកតាសំណាកគំរូបឋម (i) យោងតាមការចុះបញ្ជីភូមិ។ ក្នុង ករណីភាគច្រើន ភាពខុសគ្នានេះមានតិចតួចប៉ុណ្ណោះ។

**ជំហានទីបី** សមាមាត្រទម្ងន់សំណាកគំរូសម្រាប់គ្រួសារត្រូវបានគណនាដោយការរួមបញ្ចូលសមាមាត្រទម្ងន់ពីជំហានជ្រើសសំណាកគំរូទាំងពីរដំបូង។ សមាមាត្រទម្ងន់សំណាកគំរូ (គណនា weight) សម្រាប់គ្រួសារ (k) ក្នុងឯកតាសំណាកគំរូបឋម (1) ត្រូវបានគណនាតាមរូបមន្តខាងក្រោម៖

$$d_{hik} = W_{I.hi} \times W_{II.hi}$$

ដែល drak = គណនាសមាមាត្រទម្ងន់ ក្នុងតំបន់ (h) ឯកតាសំណាកគំរូបឋម (1) និងគ្រួសារ (k) ។ ជាទូទៅ ការកែតម្រូវសម្រាប់ការមិនឆ្លើយត្រូវបានបញ្ចូលក្នុងការគណនាសមាមាត្រទម្ងន់អង្កេត។ ជាពិសេស បើឯកតាសំណាកគំរូបឋមមានតិចជាង ១៤ គ្រួសារបានឆ្លើយ នោះសមាមាត្រទម្ងន់គួរត្រូវបានកែតម្រូវតាមកត្តា ១៤/r ដែលជាចំនួនគ្រួសារបានឆ្លើយនៅក្នុងឯកតាសំណាកគំរូបឋមដែលត្រូវពិចារណា។ ទោះជាយ៉ាងណាក៏ដោយ ដោយសារមានតែមួយករណី ដែលចំនួនគ្រួសារបានឆ្លើយមានតិចជាង ១៤ គ្រួសារ ដូច្នេះដំណើរការគណនាសមាមាត្រទម្ងន់ ត្រូវបានរំលង។

ទីបញ្ចប់ សមាមាត្រទម្ងន់គ្រួសារចុងក្រោយគឺៈ $W_{hik} = d_{hik} \times f$

ដែល $W_{hik}$ = សមាមាត្រទម្ងន់គ្រួសារចុងក្រោយ

f = កត្តាគ្រួសារក្រិតតាមខ្នាត

**តារាង ២.១ ភូមិ និងគ្រួសារសំណាកគំរូសម្រាប់អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥**

| តំបន់ | ភូមិសំណាកគំរូ | គ្រួសារសំណាកគំរូ |
|---|---|---|
| ទីប្រជុំជន | ២៧០ | ៣.៧៨ |
| ជនបទ | ៤៣៨ | ៦.១៣២ |
| **សរុប** | **៧០៨** | **៩.៩១២** |

**តារាង ២.២ ការបែងចែកសំណាកគំរូតាមតំបន់ទីប្រជុំជន និងជនបទ ក្នុងរាជធានីខេត្ត សម្រាប់អង្កេតកម្លាំងពលកម្មកម្ពុជា ឆ្នាំ២០២៥**

| រាជធានី/ខេត្ត | ចំនួនភូមិសំណាកគំរូ | | | ចំនួនគ្រួសារសំណាកគំរូ | | |
|---|---|---|---|---|---|---|
| | ទីប្រជុំជន | ជនបទ | សរុប | ទីប្រជុំជន | ជនបទ | សរុប |
| បន្ទាយមានជ័យ | ១៤ | ២៤ | ៣៨ | ១៩៦ | ៣៣៦ | ៥៣២ |
| បាត់ដំបង | ៩ | ៣៦ | ៤៥ | ១២៦ | ៥០៤ | ៦៣០ |
| កំពង់ចាម | ៦ | ៣៦ | ៤២ | ៨៤ | ៥០៤ | ៥៨៨ |
| កំពង់ឆ្នាំង | ៦ | ២០ | ២៦ | ៨៤ | ២៨០ | ៣៦៤ |
| កំពង់ស្ពឺ | ២៤ | ១៦ | ៤០ | ៣៣៦ | ២២៤ | ៥៦០ |
| កំពង់ធំ | ៣ | ២៨ | ៣១ | ៤២ | ៣៩២ | ៤៣៤ |
| កំពត | ៣ | ២៦ | ២៩ | ៤២ | ៣៦៤ | ៤០៦ |
| កណ្តាល | ៣៤ | ១៩ | ៥៣ | ៤៧៦ | ២៦៦ | ៧៤២ |
| កោះកុង | ៣ | ៣ | ៦ | ៤២ | ៤២ | ៨៤ |
| ក្រចេះ | ២ | ១៥ | ១៧ | ២៨ | ២១០ | ២៣៨ |
| មណ្ឌលគិរី | ១ | ២ | ៣ | ១៤ | ២៨ | ៤២ |
| ភ្នំពេញ | ១០១ | ០ | ១០១ | ១.៤១៤ | ០ | ១.៤១៤ |
| ព្រះវិហារ | ១ | ១០ | ១១ | ១៤ | ១៤០ | ១៥៤ |

| | | | | | | |
|---|---|---|---|---|---|---|
| ព្រៃវែង | ៣ | ៥១ | ៥៤ | ៤២ | ៧១៤ | ៧៥៦ |
| ពោធិ៍សាត់ | ៣ | ១៦ | ១៩ | ៤២ | ២២៤ | ២៦៦ |
| រតនៈគីរី | ២ | ៩ | ១១ | ២៨ | ១២៦ | ១៥៤ |
| សៀមរាប | ១៤ | ៣១ | ៤៥ | ១៩៦ | ៤៣៤ | ៦៣០ |
| ព្រះសីហនុ | ៧ | ២ | ៩ | ៩៨ | ២៨ | ១២៦ |
| ស្ទឹងត្រែង | ២ | ៥ | ៧ | ២៨ | ៧០ | ៩៨ |
| ស្វាយរៀង | ៧ | ១៩ | ២៦ | ៩៨ | ២៦៦ | ៣៦៤ |
| តាកែវ | ១៣ | ២៩ | ៤២ | ១៨២ | ៤០៦ | ៥៨៨ |
| ឧត្តរមានជ័យ | ៤ | ៨ | ១២ | ៥៦ | ១១២ | ១៦៨ |
| កែប | ២ | ០ | ២ | ២៨ | ០ | ២៨ |
| ប៉ៃលិន | ៣ | ១ | ៤ | ៤២ | ១៤ | ៥៦ |
| ត្បូងឃ្មុំ | ៣ | ៣២ | ៣៥ | ៤២ | ៤៤៨ | ៤៩០ |
| **កម្ពុជា** | **២៧០** | **៤៣៨** | **៧០៨** | **៣.៧៨** | **៦.១៣២** | **៩.៩១២** |

## ២.៦. វិធីសាស្ត្រប៉ាន់ស្មាន

ការប៉ាន់ស្មានថ្នាក់ជាតិគ្របដណ្តប់លើប្រទេសកម្ពុជាទាំងមូល [ទីប្រជុំជន (h=1) ឬជនបទ (h=2)]។ ដើម្បី ប៉ាន់ស្មានសរុបថ្នាក់ជាតិនៃចរិតលក្ខណៈប្រជាជនជាក់លាក់X គឺជាអថេរដែលរាប់បញ្ចូលគ្រួសារ (k)ឯកតា សំណាកគំរូបឋម (1) និងតំបន់ (h)។

ក្នុងទូទាំងប្រទេស ($\hat{X}$)៖ $$\hat{X} = \sum_{h=1}^{2}\sum_{i=1}^{n_{hi}}\sum_{k=1}^{m_{hik}}(X_{hik}\cdot W_{hik})$$

ក្នុងតំបន់ (h) (ទីប្រជុំជន ជនបទ) ($\hat{X}_h$)៖ $$\hat{X}_h = \sum_{i=1}^{n_{hi}}\sum_{k=1}^{m_{hik}}(X_{hik}\cdot W_{hik})$$

## ២.៧. ការចុះសម្ភាសន៍សាកល្បងតារាងសំណួរ

ការបណ្តុះបណ្តាលសម្រាប់ការចុះសាកល្បងកម្រងសំណួរមុន ត្រូវបានធ្វើឡើងរយៈពេលសរុបប្រាំមួយថ្ងៃ ហើយត្រូវបានរៀបចំឡើង ដើម្បីត្រៀមលក្ខណៈឱ្យបានគ្រប់គ្រាន់ដល់ក្រុមការងារចុះសម្ភាសន៍នៅមូលដ្ឋាន សម្រាប់ការប្រមូលទិន្នន័យឱ្យមានប្រសិទ្ធភាព។ក្នុងដំណាក់កាលដំបូងនៃការបណ្តុះបណ្តាល រយៈពេលបីថ្ងៃត្រូវបានបែងចែកសម្រាប់ការបណ្តុះបណ្តាលលើកម្រងសំណួរដែលប្រើប្រាស់ក្រដាស។ សមាសភាគនេះបានផ្តោតលើការធ្វើឱ្យអ្នកចូលរួមបានដឹងអំពីរចនាសម្ព័ន្ធ និងខ្លឹមសារនៃកម្រងសំណួរ ការបញ្ជាក់ឱ្យច្បាស់ពីគោលបំណងនៃផ្នែកនីមួយៗ និងការធានាឱ្យមានការយល់ដឹងច្បាស់លាស់នូវរាល់សំណួរ និងជម្រើសនៃចម្លើយទាំងអស់។ ការបណ្តុះបណ្តាលនេះក៏បានគ្របដណ្តប់ផងដែរនូវបច្ចេកទេសសម្ភាសន៍ ការពិចារណាលើផ្នែកសីលធម៌ នីតិវិធីនៃការយល់ព្រមបន្ទាប់ពីទទួលបានព័ត៌មាន និងការអនុវត្តជាក់ស្តែង

ដូចជា ការដើរតួសម្តែង និងការធ្វើសម្ភាសន៍សាកល្បង ដើម្បីពង្រឹងជំនាញ និងសង្គតភាព (ភាពស៊ីសង្វាក់គ្នា) របស់អ្នកសម្ភាសន៍។

បន្ទាប់ពីការបណ្តុះបណ្តាលលើកម្រងសំណួរក្រដាស រយៈពេលបីថ្ងៃបន្ថែមទៀតត្រូវបានផ្តល់ជូនសម្រាប់ការបណ្តុះបណ្តាលលើការសម្ភាសដោយប្រើប្រាស់ប្រព័ន្ធកុំព្យូទ័រ (Computer-Assisted Personal Interviewing - CAPI)។ ដំណាក់កាលនេះបានសង្កត់ធ្ងន់លើការអនុវត្តផ្ទាល់ជាមួយឧបករណ៍ប្រមូលទិន្នន័យឌីជីថល រួមមានរបៀបប្រើប្រាស់កម្មវិធី CAPI នីតិវិធីបញ្ចូលទិន្នន័យ ប្រព័ន្ធលោតរំលងសំណួរ ការត្រួតពិនិត្យភាពត្រឹមត្រូវនៃទិន្នន័យ និងការដោះស្រាយបញ្ហាបច្ចេកទេសទូទៅ។ អ្នកចូលរួមត្រូវបានណែនាំតាមរយៈការធ្វើសម្ភាសន៍បែបត្រាប់តាមដោយប្រើប្រាស់ប្រព័ន្ធ CAPI ដើម្បីបង្កើនទំនុកចិត្ត និងភាពត្រឹមត្រូវក្នុងស្ថានភាពនៅមូលដ្ឋានជាក់ស្តែង។ ជាទូទៅ ការបណ្តុះបណ្តាលនេះបានធានាថា សមាជិកក្រុមទាំងអស់ត្រូវបានរៀបចំខ្លួនយ៉ាងល្អ ដើម្បីអនុវត្តការសាកល្បងមុននេះឱ្យមានប្រសិទ្ធភាព ភាពត្រឹមត្រូវ និងស្របតាមស្តង់ដារគុណភាពទិន្នន័យដែលបានកំណត់។

ការសាកល្បងកម្រងសំណួរនៃអង្កេតកម្លាំងពលកម្មកម្ពុជាឆ្នាំ២០២៥ ។ត្រូវបានអនុវត្តចំនួនបីដងដាច់ដោយឡែកពីគ្នា ដើម្បីធ្វើតេស្ត និងកែលម្អឧបករណ៍អង្កេត នីតិវិធី និងវិធីសាស្ត្រប្រមូលទិន្នន័យមុនពេលឈានដល់ការអនុវត្តការអង្កេតថ្នាក់ជាតិជាផ្លូវការ។

ការសាកល្បងកម្រងសំណួរមុនលើកទី១ ត្រូវបានធ្វើឡើងចាប់ពីថ្ងៃទី១១ ដល់ថ្ងៃទី១៦ ខែសីហា ឆ្នាំ ២០២៥ នៅក្នុងខេត្តតាកែវ។ ការសាកល្បងជុំដំបូងនេះ បានផ្តោតសំខាន់លើការវាយតម្លៃទៅលើរចនាសម្ព័ន្ធរួមនៃកម្រងសំណួរ ភាពច្បាស់លាស់នៃសំណួរ និងប្រសិទ្ធភាពនៃនីតិវិធីចុះអនុវត្តការងារនៅមូលដ្ឋាន ក្រោមលក្ខខណ្ឌអង្កេតជាក់ស្តែង។ មតិកែលម្អពីមន្ត្រីសម្ភាសន៍ និងអ្នកត្រួតពិនិត្យត្រូវបានប្រមូលដើម្បីកំណត់រកបញ្ហានានាដែលពាក់ព័ន្ធនឹងការប្រើប្រាស់ឃ្លាឃ្លោងក្នុងសំណួរ លំដាប់លំដោយនៃសំណួរ ឬការយល់ដឹងរបស់អ្នកឆ្លើយតប។

ការសាកល្បងកម្រងសំណួរលើកទី២ បានប្រព្រឹត្តទៅចាប់ពីថ្ងៃទី០៨ ដល់ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ ២០២៥ នៅក្នុងខេត្តកំពង់ឆ្នាំង។ ការសាកល្បងជុំនេះ បានបញ្ចូលនូវរាល់ការកែសម្រួលនានាដែលបានធ្វើឡើងបន្ទាប់ពីការសាកល្បងកម្រងសំណួរលើកទី១ ដោយក្នុងគោលបំណងបន្តពិនិត្យផ្ទៀងផ្ទាត់កម្រងសំណួរ និងប្រព័ន្ធសម្ភាសន៍ដោយប្រើកុំព្យូទ័រជំនួយ(CAPI)។ ការយកចិត្តទុកដាក់ខ្ពស់ត្រូវបានផ្តោតទៅលើ លក្ខខណ្ឌរំលងសំណួរ (skip patterns) វិធាននៃការផ្ទៀងផ្ទាត់ទិន្នន័យ រយៈពេលនៃការសម្ភាស និងភាពមិនច្បាស់លាស់នៃចម្លើយនៅតាមស្ថានភាពគ្រួសារ និងស្ថានភាពមុខរបរខុសៗគ្នា។

ការសាកល្បងកម្រងសំណួរលើកទី៣ ត្រូវបានប្រព្រឹត្តទៅចាប់ពីថ្ងៃទី១៥ ដល់ថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ ២០២៥ នៅក្នុងខេត្តសៀមរាប។ ការសាកល្បងជុំចុងក្រោយនេះ មានគោលបំណងបញ្ជាក់ពីប្រសិទ្ធភាពនៃការកែសម្រួលទាំងអស់ និងដើម្បីធានាថា មន្ត្រីសម្ភាសន៍អាចអនុវត្តការអង្កេតបានយ៉ាងរលូន និងត្រឹមត្រូវ។ លើសពីនេះ វាក៏បានសាកល្បងលើការរៀបចំយន្តការត្រួតពិនិត្យ និងដំណើរការបញ្ជូនទិន្នន័យផងដែរ។ ជារួម ការសាកល្បងកម្រងសំណួរមុនទាំងបីលើកនេះ បានផ្តល់នូវធាតុចូលដ៏មានតម្លៃ ដែលរួម

ចំណែកដល់ការលើកកម្ពស់គុណភាពទិន្នន័យ និងការត្រៀមលក្ខណៈរួចរាល់សម្រាប់ការអនុវត្តពេញលេញនៃការអង្កេតកម្លាំងពលកម្ម ឆ្នាំ២០២៥។

ជំនួយបច្ចេកទេសសម្រាប់ការបណ្តុះបណ្តាលនេះ ត្រូវបានផ្តល់ជូនតាមរយៈប្រព័ន្ធនិម្មិត (Virtual) ដែលអនុញ្ញាតឱ្យសិក្ខាកាមទទួលបានការណែនាំ និងការគាំទ្រពីចម្ងាយក្នុងអំឡុងពេលដំណើរការទាំងមូល។ បេក្ខជនសរុបចំនួន ១៣ រូប បានចូលរួមក្នុងការបណ្តុះបណ្តាលកម្រងសំណួរនេះ ដែលក្នុងនោះមានស្ត្រី ៥ រូប និងបុរស ៨ រូប។ ក្រុមនេះរួមមាន៖ មន្ត្រីសម្ភាសន៍ចំនួន ៩ រូប និងអ្នកត្រួតពិនិត្យចំនួន ២ រូប មកពីវិទ្យាស្ថានជាតិស្ថិតិ (NIS) ព្រមទាំងមន្ត្រីមូលដ្ឋានពាក់ព័ន្ធផ្សេងទៀត ដែលចូលរួមក្នុងការអនុវត្តការអង្កេត។

វគ្គបណ្តុះបណ្តាលតាមប្រព័ន្ធនិម្មិតនេះ បានផ្តោតសំខាន់លើការកសាងការយល់ដឹងឱ្យបានច្បាស់លាស់អំពីខ្លឹមសារនៃកម្រងសំណួរ គោលបំណងនៃការអង្កេត និងនីតិវិធីនៃការប្រមូលទិន្នន័យ។ សិក្ខាកាមបានចូលរួមយ៉ាងសកម្មតាមរយៈការពិភាក្សា ការអនុវត្តលំហាត់ជាក់ស្តែង និងវគ្គសំណួរ-ចម្លើយ ដើម្បីធានាបាននូវសង្គតភាព (ភាពស៊ីគ្នា) និងភាពត្រឹមត្រូវក្នុងការប្រមូលទិន្នន័យ។ បេក្ខជនទាំង ១៣រូប ដែលបានបញ្ចប់ការបណ្តុះបណ្តាល ត្រូវបានរំពឹងថានឹងត្រឡប់មកចូលរួមក្នុងការអង្កេតចម្បងវិញ ដើម្បីធានាបាននូវនិរន្តរភាព ការរក្សាបាននូវជំនាញ និងការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវចំណេះដឹងដែលទទួលបានពីការបណ្តុះបណ្តាល។

